**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ០២៩៨/២១ ក.ប/ស.ជ.ណ.ន.ល

# សេចក្តីជូនដំណឹង

## ស្តីពី

## ការធ្វើបច្ចុប្បន្នភាពអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់កម្មករ និយោជិត ជូនអាជ្ញាធរមានសមត្ថកិច្ច

យោងតម្រូវការចាំបាច់របស់រដ្ឋបាលរាជធានីភ្នំពេញ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមណែនាំដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងកម្មករ និយោជិតទាំងអស់ ដូចខាងក្រោម៖

១. ចំពោះម្ចាស់ ឬនាយករោងចក្រ សហគ្រាស ត្រូវ៖

- ធ្វើបច្ចុប្បន្នភាពអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នពិតប្រាកដ (ផ្ទះលេខ/បន្ទប់ជួលលេខ, ភូមិ, ឃុំ/សង្កាត់, ក្រុង/ស្រុក/ខណ្ឌ, និងរាជធានី/ខេត្ត) របស់កម្មករ និយោជិត មកក្រសួងឱ្យបានមុនថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ ដោយ៖
  - ក្នុងករណី មិនទាន់បានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធ៖
    - ចូលទៅ https://lacms.mlvt.gov.kh/client/emp/register ដើម្បីចុះឈ្មោះប្រើប្រាស់ប្រព័ន្ធ
    - ជ្រើសរើស "Upload បញ្ជីឈ្មោះបច្ចុប្បន្នភាពរបស់កម្មករនិយោជិត"
    - ធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់កម្មករ និយោជិត
  - ក្នុងករណី បានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធរួចហើយ៖
    - ចូលទៅ https://lacms.mlvt.gov.kh ដោយប្រើប្រាស់អ៊ីម៉ែល និងលេខសម្ងាត់ ដែលបានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធ នាពេលកន្លងមក
    - ជ្រើសរើស "បច្ចុប្បន្នភាពអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់កម្មករនិយោជិត"
    - ធ្វើបច្ចុប្បន្នភាពអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់កម្មករ និយោជិតនីមួយៗ
- ណែនាំឱ្យកម្មករ និយោជិតត្រៀមរូបថត ៤x៦ ចំនួន ៣សន្លឹក និងសហការផ្តល់ព័ត៌មានអំពីអាសយដ្ឋានស្នាក់នៅបច្ចុប្បន្ន និងព័ត៌មានចាំបាច់តាមការកំណត់ ជូនអាជ្ញាធរមានសមត្ថកិច្ចនៅពេលខាងមុខ
- ម្ចាស់ ឬនាយករោងចក្រ សហគ្រាស អាចសួរព័ត៌មានបន្ថែមតាមរយៈក្រុមតេឡេក្រាម https://t.me/EmployerChat។

២. ចំពោះបងប្អូនកម្មករ និយោជិត ត្រូវ៖

- សួរទៅម្ចាស់ផ្ទះជួល ដើម្បីផ្តល់អាសយដ្ឋានស្នាក់នៅបច្ចុប្បន្នពិតប្រាកដ (ផ្ទះលេខ/បន្ទប់ជួលលេខ, ភូមិ, ឃុំ/សង្កាត់, ក្រុង/ស្រុក/ខណ្ឌ, និងរាជធានី/ខេត្ត) ទៅអ្នកទទួលបន្ទុករដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន
- ត្រៀមរូបថត ៤x៦ ចំនួន ៣សន្លឹក និងសហការផ្តល់ព័ត៌មានអំពីអាសយដ្ឋានស្នាក់នៅបច្ចុប្បន្ន និងព័ត៌មានចាំបាច់តាមការកំណត់ ជូនអាជ្ញាធរមានសមត្ថកិច្ចនៅពេលខាងមុខ
- បងប្អូនកម្មករ និយោជិត អាចសួរព័ត៌មានបន្ថែមតាមរយៈក្រុមតេឡេក្រាម https://t.me/KhmerWorkerChat។

អាស្រ័យដូចបានជម្រាបជូនខាងលើ ម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងកម្មករ និយោជិតទាំងអស់ ត្រូវចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃព្រហស្បតិ៍ ១រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន:**

- រដ្ឋបាលរាជធានីភ្នំពេញ
- គ្រប់អង្គភាព និងមន្ទីរនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- សមាគមស្បែកជើងកម្ពុជា